នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Aug-2019, 15:28
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំពេលវេលា និងចំនួនទំព័របន្ថែម សម្រាប់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS
(បម្រុង)

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម C. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Phillip RAPOZA
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក លីវ សុវណ្ណ
លោកស្រី Doreen CHEN
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

# I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាជំទាស់នឹងសំណើសុំបន្ថែមពេលវេលារហូតដល់ ៤៣០% និងបន្ថែមចំនួនទំព័ររហូតដល់៣២០០% សម្រាប់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន[1]។ ដូច ខៀវ សំផន ដែរ[2] នួន ជា ខកខានមិនបានផ្តល់យុត្តិកម្មចំពោះការស្នើសុំពេលវេលា និងចំនួនទំព័របន្ថែមយ៉ាងច្រើននេះទេ។ ខណៈដែលសហព្រះរាជអាជ្ញាពឹងផ្អែកលើសេចក្តីសន្និដ្ឋានរបស់ខ្លួន ក្នុងការឆ្លើយតបទៅនឹងសំណើរបស់ ខៀវ សំផន[3] ចម្លើយតបនេះគឺជាការចាំបាច់ដោយសារសេចក្តីថ្លែងជាច្រើនដែលបានធ្វើឡើងដោយ នួន ជា នាំឲ្យមានការយល់ច្រឡំ។

# II. ប្រវត្តិនីតិវិធី

2. សាលក្រមសំណុំរឿង០០២/០២ បានចេញជាសេចក្តីសង្ខេបនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨[4]។ នៅក្នុងសាលក្រមនោះ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសម្រេចខាងផ្លូវច្បាប់របស់ខ្លួន នៅលើគោលនយោបាយរបស់ បកក និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាក់ទងនឹងសហករណ៍ និងការដ្ឋាននានា មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ការកំណត់គោលដៅចំពោះចាម វៀតណាម ពុទ្ធសាសនិកជន និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងការប្បញ្ញត្តិអំពីអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះសាលាដំបូង បានចង្អុលបង្ហាញពីឧក្រិដ្ឋកម្មដែលខ្លួនមានភ័ស្តុតាងហួសពីវិមតិសង្ស័យ និងឧក្រិដ្ឋកម្មដែលបានលើកលែងចោទប្រកាន់[5]។ អង្គជំនុំជម្រះក៏បានពន្យល់ពីទម្រង់នៃការទទួលខុសត្រូវដែលនួន ជា និង ខៀវ សំផន ត្រូវទទួលខុសត្រូវ និងឧក្រិដ្ឋកម្មដែលត្រូវបានពិចារណាថាមិនបានបំពេញតាមបទដ្ឋានផងដែរ[6]។

---

[1] ឯកសារ F47 សំណើលើកទីមួយរបស់ នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ សម្រាប់ដាក់សារណាលើបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០២, ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ ("សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា")។

[2] *សូមមើល* ឯកសារ F45/2 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ សម្រាប់សារណាបណ្តឹងសាទុក្ខ, ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ("ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន"), កថាខណ្ឌ ៦-១៦, ២១។

[3] ឯកសារ F45/2 ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។

[4] សាលក្រមសំណុំរឿង០០២/០២, ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ("សាលក្រមសង្ខេប")។

[5] សាលក្រមសង្ខេប, ទំព័រ ៥-១៩, ២៩-៣១។

[6] សាលក្រមសង្ខេប, ទំព័រ ១៩-២៧។

3. ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមពេញលេញរបស់ខ្លួន[7]។ នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ នួន ជា បានដាក់សំណើរបស់គាត់ ដោយបានស្នើរយៈពេលបន្ថែម ១៥០ថ្ងៃ (សរុប១៨០ថ្ងៃ) និង៧០ទំព័រ (សរុប១០០ទំព័រ) ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់[8] ដោយគូសបញ្ជាក់ថា នេះគ្រាន់តែសំណើលើកទីមួយសម្រាប់ការសុំពេលវេលា និងចំនួនទំព័របន្ថែមសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប៉ុណ្ណោះ[9]។ នៅថ្ងៃដដែល ខៀវ សំផន ក៏បានស្នើសុំបន្ថែមពេលវេលាចំនួន២៤០ថ្ងៃ និងចំនួនទំព័រសរុបដល់១០០ទំព័រ ជាភាសាបារាំង ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់[10]។

4. នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ការអនុញ្ញាតតាមសំណើសុំរបស់ភាគី ដោយបន្ថែមរយៈពេល២ខែ និបន្ថែមទំព័រពី៣០ ដល់៦០ សម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[11]។ នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ នួន ជា បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់ ដោយចោទថា គាត់មានទទ្បីករណ៍ចំនួន៣៥១ សម្រាប់ជាមូលដ្ឋាននៃបណ្តឹងសាទុក្ខ និងសេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបានចំនួន២៤[12]។ ក្នុងថ្ងៃតែមួយ ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់គាត់[13] ដោយអះអាងថា គាត់មាន

---

[7] ឯកសារ **E465** សំណុំរឿង ០០២/០២ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។

[8] ឯកសារ **F40/1.1** សំណើបន្ទាន់លើទីមួយរបស់ នួន ជា សុំចំនួនទំព័រនិងពេលវេលាបន្ថែមសម្រាប់ការដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០២, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩(“សំណើរបស់ នួន ជា សុំបន្ថែមពេលវេលានិងចំនួនទំព័រសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ”), កថាខណ្ឌ១។

[9] ឯកសារ **F40/1.1** សំណើរបស់ នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ, កថាខណ្ឌ ៣៥។

[10] ឯកសារ **F39/1.1** សំណើរបស់លោក ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩, កថាខណ្ឌ ៤២។

[11] ឯកសារ **F43** សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ, ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ (“សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ”), កថាខណ្ឌ ១១។

[12] ឯកសារ **E465/3/1** សេចក្តីជូនដំណឹងរបស់ នួន ជា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០២, ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ (“សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា”)។ **F47** សំណើរបស់ នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រ កថាខណ្ឌ២៩។

[13] ឯកសារ **E465/4/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង០០២/០២) ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩។

ទឡ្ហីករណ៍១៨២៤ សម្រាប់ជាមូលដ្ឋាននៃបណ្តឹងសាទុក្ខ និងសេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបានចំនួន៣៥៥[14]។

5. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ ខៀវ សំផន បានស្នើសុំបន្ថែមពេលវេលារហូត ១០.៥ខែ និងចំនួនទំព័រសរុប៩៥០ទំព័រ សម្រាប់បណ្តឹងសាទុក្ខរបស់គាត់[15]។ សហព្រះរាជអាជ្ញាបានជំទាស់នឹងសំណើនេះនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ដោយផ្អែកលើមូលហេតុថា ពេលវេលា និងចំនួនទំព័រដែលបានស្នើសុំនោះ មិនធ្លាប់មានពីមុន និងមិនអាចធ្វើយុត្តិកម្មបានឡើយ[16]។ ក្នុងថ្ងៃតែមួយពេលដែលចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំរបស់ ខៀវ សំផន ចូលមកដល់នោះ នួន ជា ក៏បានដាក់អ្វីដែលគាត់ថាជាសំណើ"លើកទីមួយ"របស់គាត់ សុំបន្ថែមពេលវេលារហូតដល់ ១០.៥ខែ និងបន្ថែមចំនួនទំព័រកំណត់សរុប១០០០ទំព័រ សម្រាប់បណ្តឹងសាទុក្ខរបស់គាត់[17]។

## III. ចម្លើយតប

### *(i) នួន ជា យល់ខុសចំពោះបទដ្ឋានសម្រាប់ការពិនិត្យលើបណ្តឹងសាទុក្ខ*

6. ផ្ទុយទៅនឹងការទាមទាររបស់ នួន ជា ដែលថា "បទដ្ឋានសម្រាប់ការពិនិត្យលើបណ្តឹងសាទុក្ខនៅ អ.វ.ត.ក" គាំទ្រចំពោះសំណើច្រើនលើសលប់របស់គាត់[18]។ បទដ្ឋានសម្រាប់ការពិនិត្យលើបណ្តឹងសាទុក្ខ មិនខុសគ្នាពីករណីមុនៗក្នុងសំណុំរឿង០០២/០២ទេ ដោយសារវាបង្ហាញជាតួយ៉ាងចំពោះការពិតដែលថា នួន ជា គាំទ្រចំពោះការតវ៉ារបស់គាត់ តាមរយៈការយោងទៅរកសាលដីកាសំណុំរឿង០០១[19]។ ដូច្នេះ គ្មានការអនុវត្តនៅ អ.វ.ត.ក ដើម្បីបង្ហំឲ្យមានការសន្និដ្ឋានថា សំណើសុំពេលវេលាច្រើនលើសលប់របស់ នួន ជា ជាយុត្តិកម្មសមស្របដែលផ្អែកលើបទដ្ឋានសម្រាប់ការពិនិត្យលើបណ្តឹងសាទុក្ខ។ សហព្រះរាជអាជ្ញាយល់ស្របជាមួយ នួន ជា ថា បទដ្ឋានសម្រាប់ការពិនិត្យលើបណ្តឹងសាទុក្ខ "មានន័យថា ភាគីដែលដាក់បណ្តឹងសាទុក្ខ ត្រូវតែអាចបង្កើតទឡ្ហីករណ៍សម្រាប់បណ្តឹងសាទុក្ខ និងផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ ដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការ

[14] ឯកសារ F45 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់សារណាបណ្តឹសាទុក្ខរបស់ ខៀវ សំផន, កថាខណ្ឌ៩។

[15] ឯកសារ F45 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់សារណាបណ្តឹសាទុក្ខរបស់ខៀវ សំផន, កថាខណ្ឌ១៩។

[16] ឯកសារ F45/2 ចម្លើយតបរបស់ កសព ទៅនឹងសំណើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័របណ្តឹងសាទុក្ខរបស់ ខៀវ សំផន។

[17] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា កថាខណ្ឌ ១។

[18] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា, កថាខណ្ឌ ៤២។

[19] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា, កថាខណ្ឌ ៤២។

ពិតិត្យ”[20]។ ក៏ប៉ុន្តែ ការណ៍នេះហាក់ដូចជាពិតចំពោះអ្វីដែលបណ្តឹងសាទុក្ខមានប្រសិទ្ធភាពមួយគួរតែមាន តែមិនមែនជាអំណះអំណាងមួយដែលគាំទ្រដល់សំណើសុំ ដែលមិនធ្លាប់មានពីមុនមកនោះទេ។

7. នួន ជា ក៏ចង្អុលបង្ហាញមិនត្រឹមត្រូវផងដែរ ចំពោះការវិភាគផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះតុលាការកំពូល និងសវនាការលើភ័ស្តុតាងបន្ថែមនៅក្នុងសាលដីកាសំណុំរឿង០០២/០១ ដែលឲ្យដឹងថា គាត់ “ត្រូវការពេលវេលា និងចំនួនទំព័របន្ថែមយ៉ាងច្រើន” ដើម្បីលើកឡើងនូវទឡ្ហីករណ៍ដែលអាចទទួលយកបាន និងបំពេញទៅតាមបទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះ”[21]។ នួន ជា ចង់បង្កប់ន័យថា អង្គជំនុំជម្រះតុលាការកំពូលមិនអាចបំពេញតួនាទីរបស់ខ្លួនឡើយ ប្រសិនបើគាត់មិនបានធ្វើសារណាសន្និដ្ឋានឲ្យបានច្រើនលើសលប់ អំពីទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់គាត់ទេនោះ។ ការណ៍នេះ គឺមិនត្រឹមត្រូវទេ ហើយផ្ទុយគ្នាផងដែរដោយហេតុថា គាត់បន្តទាមទារថាគាត់គ្មានពេលវេលា និងឱកាសគ្រប់គ្រប់សម្រាប់បណ្តឹងសាទុក្ខសំណុំរឿង០០២/០១ របស់គាត់[22] ប៉ុន្តែក្នុងពេលជាមួយគ្នា គាត់និយាយថា អង្គជំនុំជម្រះតុលាការកំពូល “ក្រោយពេលធ្វើការវិភាគយ៉ាងប្រុងប្រយ័ត្នលើអង្គហេតុនានារួចមក [...] អាចធ្វើការលើកលែងការចោទប្រកាន់មួយចំនួន ក្នុងសំណុំរឿង០០២/០១”[23]។

### *(ii) សំណើសុំច្រើនហួសហេតុរបស់ នួន ជា មិនតំណាងឲ្យ “ពេលវេលាគ្រប់គ្រាន់” សម្រាប់ការត្រៀមរៀបចំការការពារក្តីរបស់ខ្លួនទេ ហើយក៏មិនត្រឹមត្រូវទៅនឹងការអនុវត្តជាអន្តរជាតិដែរ*

8. ខណៈ នួន ជា អះអាងត្រឹមត្រូវ ថាគាត់គួរតែមានពេលវេលា និងបរិក្ខាគ្រប់គ្រាន់ក្នុងការត្រៀមរៀបចំការការពារក្តីរបស់គាត់ តែគាត់បានធ្វើឲ្យខូចដល់កេរ្តិ៍ឈ្មោះខ្លួនឯងដែរ ដោយសារគាត់ចាត់ទុកថា សំណើសុំបន្ថែមពេលវេលារហូតដល់១០.៥ខែ និង១០០០ទំព័រ សម្រាប់សារណានៃបណ្តឹងសាទុក្ខរបស់គាត់ថា “សមហេតុផល”[24] “កម្រិតអប្បបរមាដែលចាំបាច់”[25] និង “ស៊ីចង្វាក់គ្នាជាខ្លាំង”[26]។ ដំបូង នួន ជា ពឹងផ្អែកទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍

[20] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា, កថាខណ្ឌ ៤៣។

[21] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា, កថាខណ្ឌ ៤៤។

[22] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា, កថាខណ្ឌ ៣៩។

[23] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា, កថាខណ្ឌ ៤៤។

[24] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា, កថាខណ្ឌ ៣៦។

[25] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា, កថាខណ្ឌ ៣៥។

[26] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា, កថាខណ្ឌ ៣៨។

ដែលជាយន្តការសល់ពីអន្តរជាតិរបស់តុលាការព្រហ្មទណ្ឌ ក្នុងករណី *Karadžić* និង *Mladić* ថា បានទទួលស្គាល់សិទ្ធិទទួលបានពេលវេលា និងចំនួនទំព័រគ្រប់គ្រាន់សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខប្រកបដោយអត្ថន័យ[27]។ យ៉ាងណាមិញ ការបន្ថែមពិតប្រាកដដែលទទួលបាននៅក្នុងករណីទាំងពីរនេះ មិនអាចប្រៀបធៀបបានជាមួយនឹងសំណើរបស់ នួន ជា ទេ។ Karadžić និង Mladić ត្រូវបានផ្តល់ជូននូវពេលវេលា និងទំព័របន្ថែមប្រហែល៤0% (១៣៥ថ្ងៃ) និង២៥% (២៥០ទំព័រ) នៃពេលវេលា និងចំនួនទំព័រដែលបានស្នើសុំដោយ នួន ជា[28]។ ជាការកត់សម្គាល់មានករណីដែលមានជនជាប់ចោទតែម្នាក់ក្នុងករណីនីមួយៗ ដែលមានសាលក្រមវែងជាងករណីបច្ចុប្បន្ន[29] ដែលវារឹតតែធ្វើឱ្យសំណើសុំរបស់ នួន ជា កាន់តែឃ្លាតឆ្ងាយពីខ្សែបន្ទាត់នៃបទដ្ឋានអន្តរជាតិ សម្រាប់ករណីដែលអាចប្រៀបធៀបបាន។

9. ទីពីរ សេចក្តីថ្លែងរបស់ នួន ជា អំពីពេលវេលា ដែលបានផ្តល់សម្រាប់សារណាបណ្តឹងសាទុក្ខនៅក្នុងករណី *Karadžić* និង *Mladić* គឺជាការយល់ខុស[30]។ នួន ជា មិនបានគិតថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងករណី *Karadžić* និង *Mladić* បានផ្តល់ជូនដល់ភាគីនូវពេលវេលា ១៣៥ថ្ងៃ សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខរបស់ពួកគេទេ[31]។ ផ្ទុយទៅវិញ គាត់រាប់ពេលវេលាចាប់ពីពេលចេញសាលក្រមរបស់សាលាដំបូង រហូតដល់ពេលដាក់សារណាបណ្តឹងសាទុក្ខ ដោយសារគាត់រាប់បញ្ចូលទាំងថិរវេលា ដែលបានផ្តល់ជូនភាគី សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ពួកគេដូច្នេះ ទើបធ្វើឱ្យមានសន្និដ្ឋានថា មេធាវីការពារក្តីក្នុងករណីទាំងនោះមាន "ពេលវេលាច្រើនជាង៨ខែ សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខរបស់ពួកគេ"[32]។

10. បើសិនជា នួន ជា មានភាពស្របគ្នាក្នុងការធ្វើអំណះអំណាងរបស់គាត់ ដូច្នេះពេលវេលា ១០.៥ខែ ដែលគាត់បានស្នើសុំ គួរតែត្រូវបានបន្ថយបីខែ បើសិនជាពេលវេលាដែលគាត់បានស្នើសុំត្រូវបានផ្តល់ជូនតាមសំណើដោយអង្គជំនុំជម្រះតុលាការកំពូល សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹង

[27] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា, កថាខណ្ឌ ១៦ ជើងទំព័រ២៧។

[28] ឯកសារ F45/2 ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន, កថាខណ្ឌ ១៥-១៦។

[29] ឯកសារ F45/2 ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន, កថាខណ្ឌ ១៥។

[30] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា, កថាខណ្ឌ ៤៥។

[31] *សូមមើល* ចម្លើយតបរបស់ កសព ទៅនឹងសំណើសុំរបស់ ខៀវ សំផន, កថាខណ្ឌ ១៦។

[32] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា, កថាខណ្ឌ ៤៥។

សាទុក្ខរបស់គាត់[33]។ ជាការបន្ថែម ការគណនានេះគួរតែមានការគិតគូរអំពីរយៈពេលបួនខែបន្ថែម ដែលមេធាវីការពារក្ដី នួន ជា ត្រូវត្រៀមរៀបចំសម្រាប់ដំណើរការបណ្ដឹងសាទុក្ខ នៅក្រោយពេល ដែលសាលក្រមសង្ខេបបានចេញនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨[34]។

11. ទីបី នួន ជា ទាមទារទាំងមិនត្រឹមត្រូវថា ករណី *Karadžić* និង *Mladić* គឺជារឿងក្ដីតូចជាងសំណុំរឿង០០២/០២ឆ្ងាយណាស់។ គាត់និយាយថាករណី *Karadžić* និង *Mladić* "**ពាក់ព័ន្ធតែប្រធានបទដែលមានកំណត់ប៉ុណ្ណោះ** បើប្រៀបធៀបនឹងវិសាលភាពភូមិសាស្ត្រ និងពេលវេលានៃសំណុំរឿង០០២/០២"[35]។ ការវាយតម្លៃត្រឹមត្រូវអំពីករណីទាំងនេះ បង្ហាញឲ្យឃើញផ្ទុយគ្នា។ សាលក្រមក្នុងរឿងក្ដីទាំងពីរគឺ *Karadžić* និង *Mladić* គ្របដណ្ដប់ទៅលើសហឧក្រិដ្ឋកម្មរួម ("JCE") ដាច់ដោយឡែក និងខុសៗគ្នាទាំងបួន៖[36] (i) JCE ទាំងអស់នៅបូស្នៀ និងហឺស៊ីហ្គូវីណា ដើម្បីដកចេញជាអចិន្ត្រៃយ៍នូវបូស្នៀមូស្លីម និងបូស្នៀក្រូអាត ពីទឹកដីដែលបានអះអាងដោយបូស្នៀស៊ែប[37]។ (ii) JCE ដែលបង្កើត និងអនុវត្តយុទ្ធនាការបាញ់ស៊ីប និងបាញ់ផ្លោងដើម្បីបង្កភាពតក់ស្លុតនៅក្នុងចំណោមប្រជាជនស៊ីវិលនៅសារ៉ាជីវ៉ូ[38]។ (iii) JCE ការចាប់បុគ្គលិក អ.ស.ប ធ្វើជាចំណាប់ខ្មាំងដើម្បីបង្ខំឲ្យណាតូ កុំឲ្យវាយប្រហារតាមផ្លូវអាកាសប្រឆាំងគោលដៅយោធាសៀបបូស្នៀ[39] និង (iv) JCE ការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ប្រឆាំងមូស្លីមបូស្នៀ នៅស្រ្រិប្រិនីកា តាមរយៈការសម្លាប់បុរស និងក្មេងប្រុស និងការដកចេញដោយបង្ខំនូវស្ត្រី កុមារនិងមនុស្សចាស់[40]។

---

[33] *សូមមើល* F43 សេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ កថាខណ្ឌ១១។

[34] *សូមមើល* F41 ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់មេធាវីការពារក្ដីសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ, ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩, កថាខណ្ឌ ៩-១១ ("ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើរបស់មេធាវីការពារក្ដីសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ")។

[35] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់របស់ នួន ជា, កថាខណ្ឌ ៤៧ (សង្កត់ន័យដើម)។

[36] *រដ្ឋអាជ្ញា ទល់នឹង* Radovan *Karadžić*, IT-95-5/18-T, ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ("សាលក្រមរបស់ *Karadžić*") កថាខណ្ឌ ៣, ៦០៤៦-៤៩។ *រដ្ឋអាជ្ញា ទល់នឹង* Ratko *Mladić*, IT-09-92-T, ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ("សាលក្រមរបស់ *Mladić*") កថាខណ្ឌ ៥១៨៨-៩២។

[37] សាលក្រមរបស់ *Karadžić*, កថាខណ្ឌ ៥៩៩៦។ សាលក្រមរបស់ *Mladić*, កថាខណ្ឌ ៤៦១២, ៤៦៨៨។

[38] សាលក្រមរបស់ *Karadžić*, កថាខណ្ឌ ៥៩៩៧។ សាលក្រមរបស់ *Mladić*, កថាខណ្ឌ ៤៨៩៣, ៤៩២១។

[39] សាលក្រមរបស់ *Karadžić*, កថាខណ្ឌ ៥៩៩៩។ សាលក្រមរបស់ *Mladić*, កថាខណ្ឌ ៥១៥៦, ៥១៦៣។

[40] សាលក្រមរបស់ *Karadžić*, កថាខណ្ឌ ៥៩៩៨។ សាលក្រមរបស់ *Mladić*, កថាខណ្ឌ ៤៩២២, ៥១៣០-៣១។

12. អំពីពេលវេលា និងភូមិសាស្ត្រ សាលក្រមរបស់ *Karadžić* បានគ្របដណ្តប់លើរយៈពេលពីខែតុលា ឆ្នាំ១៩៩១ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៥[41] រួមបញ្ចូលទាំងសារ៉ាជីវ៉ូ ស្រ៊ិប្រ៊ិនីកា និងសហគមន៍ចំនួន ២០ ក្នុងតំបន់ស្វយ័តនៃក្រាជីណា (Krajina) និងហៀស៊ិហ្គូវីណាភាគខាងកើត[42] ចំណែកសាលក្រម *Mladić* លាតសន្ធឹងចាប់ពីថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩២ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៥[43] ដោយមានរួមបញ្ចូលទាំង Sarajevo, Srebrenica, Goražde និងសហគមន៍ Bosnia-Herzegovina នៃ Banja Luka, Bijeljina, Foča, Ilidža, Kalinovik, Ključ, Kotor Varoš, Novi Grad, Pale, Prijedor, Rogatica, Sanski Most, Sokolac និង Vlasenica។[44] ដូច្នេះ ការកំណត់របស់ នួន ជា លើករណីទាំងនេះដែលបាន "កម្រិត" ជាសារធាតុ ជាពេលវេលា និងជាភូមិសាស្ត្រ ដោយការប្រៀបធៀបទៅនឹងសំណុំរឿង០០២/០២ គឺមិនត្រឹមត្រូវឡើយ។

13. ចុងបញ្ចប់ ការលើកឡើងថា ១០០០ទំព័រ នឹងធ្វើឲ្យមាន"សារណាបណ្តឹងសាទុក្ខស៊ីសង្វាក់គ្នាដែលនឹងជួយដល់អង្គជំនុំជម្រះក្នុងការចេញសេចក្តីសម្រេច [និង] ជួយសម្រួលនូវដំណើរការទាំងមូលនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនោះ"[45] គឺខុសស្រឡះ។ ការអនុញ្ញាតឲ្យ ១០០០ទំព័រ ទៅក្រុមមេធាវីការពារក្តីនីមួយៗ ជាលទ្ធផល នឹងធ្វើឲ្យសារណាបណ្តឹងសាទុក្ខ មានចំនួនសរុបស្មើរតែដូចគ្នាទៅនឹងចំនួនទំព័រនៃសាលក្រមដូច្នោះដែរ។ ពេលវេលាបន្ថែមដែលត្រូវការសម្រាប់ផលិតឲ្យបាន ១០០០ទំព័រនេះ នឹងធ្វើឲ្យមានការពន្យារពេលយ៉ាងច្រើន ក្នុងពេលវេលាដែលអង្គជំនុំជម្រះតុលាការកំពូល អាចនឹងចាប់ផ្តើមពិភាក្សាសម្រេចលើសំណើនេះ ក៏ដូចជានាំឲ្យមានកំណើនយ៉ាងឆាប់រហ័សនូវចំនួនទំព័រដែលត្រូវការសម្រាប់ការពិនិត្យនៅពេលបកប្រែរួច។

## *(iii) ការប្រៀបធៀបរបស់ នួន ជា អំពីវិសាលភាពនៃបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ និងសំណុំរឿង០០២/០២ គឺជាការយល់ខុស*

14. ក្នុងការធ្វើយុត្តិកម្មសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ច្រើនហួសរបស់គាត់ នួន ជា ថ្លែងថាគាត់បានកំណត់អត្តសញ្ញាណ "កំហុសយ៉ាងហោចណាស់ចំនួន ៥៤៣" នៅក្នុងសាលក្រមសំណុំរឿង០០២/០២ តាមរយៈការប្រៀបធៀបទៅនឹង "មូលដ្ឋានបណ្តឹងសាទុក្ខចំនួន ២២៣"

---

[41] សាលក្រមរបស់ *Karadžić*, កថាខណ្ឌ ៥៩៩០។

[42] *រដ្ឋអាជ្ញា ទល់នឹង Radovan Karadžić,* MICT-13-55-A, ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩, កថាខណ្ឌ ៤៤៦។

[43] សាលក្រមរបស់ Mladić, កថាខណ្ឌ ៥១៩២។

[44] សាលក្រមរបស់ Mladić, កថាខណ្ឌ ៤៦៨៥។

[45] ឯកសារ **F47** សំណើសុំបន្ថែមពេលវេលារបស់ នួន ជា កថាខណ្ឌ ១៩។

ក្នុងសំណុំរឿង០០២/០១។[46] ទោះជាយ៉ាងណា គាត់កំពុងបន្ថែមទឡ្ហីករណ៍រងទៅលើចំនួនសរុបមួយ និងមិនទៅលើចំនួនផ្សេងទៀតទេ។ ប្រសិនបើគិតយ៉ាងត្រឹមត្រូវនោះ នួន ជា ចោទប្រកាន់ទឡ្ហីករណ៍ចំនួន ៣៥១ នៅក្នុងសំណុំរឿង០០២/០២[47] ធៀបទៅនឹងទឡ្ហីករណ៍ចំនួន ២២៣ ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១។[48]

15. ស្រដៀងគ្នានេះដែរ នួន ជា បកស្រាយខុសអំពីការប្រៀបធៀបបន្ទុកការងាររវាងបណ្តឹងសាទុក្ខទាំងពីរ ដោយបានកត់សម្គាល់សេចក្តីសម្រេចចំនួន ២៤ ដែលគាត់កំពុងដាក់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលសម្រាប់ធ្វើការពិនិត្យក្នុងសំណុំរឿង០០២/០២[49] ខណៈដែលខកខានមិនបានលើកឡើងថា នៅក្នុងសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងសាទុក្ខនៃសំណុំរឿង០០២/០១ គាត់បានតវ៉ា "សេចក្តីសម្រេចចំនួន ១៦ របស់អង្គជំនុំជម្រះសាលាដំបូងបន្ថែមទៅលើសាលក្រមដែលភាគច្រើនពាក់ព័ន្ធនឹងសេចក្តីសម្រេចដោយផ្ទាល់មាត់ជាច្រើននៅក្នុងពេលសវនាការ"[50]។ ជាលទ្ធផល ការលើកឡើងរបស់ នួន ជា ដែលថា បណ្តឹងសាទុក្ខរបស់គាត់ប្រឆាំងនឹងសេចក្តីសម្រេចចំនួន ២៤ ក្នុងអំឡុងពេលសំណុំរឿង០០២/០២ នឹងចាំបាច់ត្រូវការសារណាចំនួន ៧២០ ទំព័រ ប្រសិនបើមានបណ្តឹងសាទុក្ខបន្ទាន់បង្ខំ[51]នោះ ខកខានមិនបានពិចារណាអំពីការអនុវត្តរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២/០១។ នៅពេលនោះ នួន ជា បានចោទប្រកាន់ទឡ្ហីករណ៍បណ្តឹងសាទុក្ខចំនួន ២២៣ និងសេចក្តីសម្រេចបន្ទាន់បង្ខំចំនួន ១៦ ហើយទទួលបានសរុបចំនួន ៩០ ថ្ងៃ និង ២៧០ ទំព័រ[52]។ ច្បាស់ណាស់ ការគណនាបច្ចុប្បន្នរបស់ នួន ជា មិនតម្រូវឲ្យមានការបន្ថែមរយៈពេល ១០,៥ ខែ និង ១០០០ ទំព័រនោះទេ នៅពេលដែលធៀបទៅនឹងការបន្ថែមដែលផ្តល់ជូននៅក្នុងសំណុំរឿង០០២/០១។

---

[46] ឯកសារ F47 សំណើសុំបន្ថែមពេលវេលារបស់ នួន ជា កថាខណ្ឌ ២៧។

[47] ឯកសារ E465/3/1 សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា។

[48] ឯកសារ E313/1/1 សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។

[49] ឯកសារ F47 សំណើសុំបន្ថែមពេលវេលារបស់ នួន ជា កថាខណ្ឌ ២៧។

[50] ឯកសារ F6 សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ៨។

[51] ឯកសារ F47 សំណើសុំបន្ថែមពេលវេលារបស់ នួន ជា កថាខណ្ឌ ២៩, ៣៤។

[52] ឯកសារ F9 សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ១៥, ១៧-១៨។ ("សេចក្តីសម្រេចលើសំណើសុំពន្យារក្នុងសំណុំរឿង០០២/០១")។ ឯកសារ F13/2 សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៥-១៦។

### *(iv) ការអះអាងរបស់ នួន ជា អំពីភាពថ្មី និងភាពស្មុគស្មាញនៃសំណុំរឿង០០២/០២ គឺជាការយល់ខុស*

16. ទោះបីជាសហព្រះរាជអាជ្ញាទទួលស្គាល់ភាពស្មុគស្មាញនៃសំណុំរឿង០០២/០២ និងភាពថ្មីនៃបញ្ហាមួយចំនួន ដែលបានលើកឡើងនៅក្នុងអំឡុងពេលជំនុំជម្រះ ចំណុចមួយចំនួនក្នុងចំណោមបញ្ហាទាំងនោះដែលបានលើកឡើងដោយ នួន ជា ថា "មិនត្រូវបានយកមកដោះស្រាយពីមុនមកដោយតុលាការ ឬសាលាក្តីព្រហ្មទណ្ឌអន្តរជាតិ មិនត្រឹមតែនៅ អ.វ.ត.ក ប៉ុណ្ណោះទេ"[53] មិនមែនជាបញ្ហាថ្មីដូចដែលគាត់បានអះអាងនោះទេ។ ឧទាហរណ៍ នួន ជា ដាក់បញ្ចូល "និយមន័យនៃអាពាហ៍ពិពាហ៍ដោយបង្ខំ" និង "អំពើជាមូលដ្ឋានដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ១៩៧៥" ថាជាបញ្ហាច្បាប់ថ្មីមួយចំនួន[54]។ ទោះជាយ៉ាងណា បញ្ហាទាំងពីរនេះទាក់ទងទៅនឹងនិយមន័យនៃអំពើអមនុស្សធម៌ផ្សេងៗទៀត[55] ជារឿងរ៉ាវដែលបានដោះស្រាយរួចហើយនៅក្នុងឱកាសជាច្រើននៅ អ.វ.ត.ក និងលើសពីនេះទៀត[56]។ ស្រដៀងគ្នានេះដែរ ការដាក់បញ្ចូលរបស់ នួន ជា អំពី "ភាពស្របច្បាប់នៃការកំណត់បទល្មើសឡើងវិញនូវអង្គហេតុនានាក្នុងដំណាក់កាលពិភាក្សាដើម្បីចេញសេចក្តីសម្រេចដោយមិនបានជូនដំណឹងជាមុនដល់ជនជាប់ចោទ"[57] ថាជាបញ្ហាថ្មីនោះ មើលរំលងថា វិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក បញ្ជាក់ច្បាស់ថា ការកំណត់អង្គហេតុអាចកើតឡើងនៅពេលណាមួយក្នុងកិច្ចដំណើរការនីតិវិធី និងថា ជាលទ្ធផល ភាគីទាំងឡាយត្រូវបានជូនដំណឹងអំពីលទ្ធភាពនេះនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល។[58]

---

[53] ឯកសារ **F47** សំណើសុំបន្ថែមពេលវេលារបស់ នួន ជា កថាខណ្ឌ ៤០។

[54] ឯកសារ **F47** សំណើសុំបន្ថែមពេលវេលារបស់ នួន ជា កថាខណ្ឌ ៤០។

[55] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា មានរួមបញ្ចូលតែអំពើជាមូលដ្ឋានទាក់ទងនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតប៉ុណ្ណោះ។ *សូមមើល* ឯកសារ **E465/3/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា ទឡ្ហីករណ៍ទី ៥០។

[56] *សូមមើល* ឯកសារ **F36** សាលដីកាក្នុងសំណុំរឿង០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ("សាលដីកាក្នុងសំណុំរឿង ០០២/០១") កថាខណ្ឌ ៥៧៦-៥៨៦, ៥៨៩។ *រដ្ឋអាជ្ញា ទល់នឹង* *Milomir Stakić*, IT-97-24-A, សាលក្រម, ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦, កថាខណ្ឌ ៣១៥-៣១៦។

[57] ឯកសារ **F47** សំណើសុំបន្ថែមពេលវេលារបស់ នួន ជា កថាខណ្ឌ ៤០។

[58] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្ម ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥) ("វិធានផ្ទៃក្នុង") វិធាន ៩៨(២)។ ឯកសារ **F36** សាលដីកាក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៦២។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៤៩២-៥០០។ ឯកសារ **E100/6** សំណុំរឿង០០២/០១ សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ២៤-២៥។

### (v) នួន ជា ខកខានមិនបានថ្លឹងថ្លែងឲ្យបានត្រឹមត្រូវអំពីតម្រូវការចាំបាច់សម្រាប់ការសន្សំសំចៃរបស់តុលាការក្នុងការសម្រេចអំពីការបន្ថែមពេលវេលា និងចំនួនទំព័រលើបណ្តឹងសាទុក្ខ

17. ដើម្បីធ្វើយុត្តិកម្មបន្ថែមទៀតលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ច្រើនហួសហេតុរបស់គាត់ នួន ជា ដកស្រង់ខុសនូវការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលថា ការកំណត់ចំនួនទំព័រ "ត្រូវកំណត់ទៅតាមសេចក្តីត្រូវការចាំបាច់របស់ភាគី"[59] ដោយលុបចោលគោលជំហរដែលនៅសេសសល់របស់តុលាការដែលថា តម្រូវការរបស់ភាគីទាំងឡាយត្រូវតែ "*មានតុល្យភាពជាមួយនឹងគោលការណ៍ប្រសិទ្ធភាពរបស់តុលាការ*"[60]។

18. សូម្បីតែការទទួលយកចំណុចរបស់ នួន ជា ដែលថា ការកំណត់ចំនួនទំព័រគ្រាន់តែដើម្បីតម្រូវតាមតម្រូវការចាំបាច់របស់ភាគី និងថា "ការបន្ថែមពេលវេលា និងបន្ថែមចំនួនទំព័រត្រូវតែផ្តោតទៅលើវិសាលភាពដែលបានស្នើឡើងនៃបណ្តឹងសាទុក្ខរបស់មេធាវី"[61]ក៏ដោយ ក៏សំណើរបស់គាត់ពិតជាខុសពី ខៀវ សំផន ទាំងស្រុងចំពោះពេលវេលា និងចំនួនទំព័រ។ ជាក់ស្តែង ខៀវ សំផន បានលើកឡើងទទ្បីករណ៍បណ្តឹងសាទុក្ខចំនួន១៨២៤ និងសេចក្តីសម្រេចដែលចោទប្រកាន់ដែលអាចប្តឹងសាទុក្ខបានចំនួន៣៥៥ ខណៈដែល នួន ជា ស្នើសុំចំនួនពេលវេលាដូចគ្នា និង*ថែមទាំង* ចំនួនទំព័រច្រើនជាងទៅទៀត ដើម្បីលើកឡើងនូវទឡ្ហីករណ៍បណ្តឹងសាទុក្ខចំនួន ៣៥១ និងសេចក្តីសម្រេចដែលចោទប្រកាន់ដែលអាចប្តឹងសាទុក្ខបានចំនួន២៤។ សំណើសុំពេលវេលា និងចំនួនទំព័រ មិនសមហេតុផលក្នុងចំណុចទាំងពីរ ប៉ុន្តែភាពមិនស្របគ្នារវាងវិសាលភាពនៃបណ្តឹងសាទុក្ខនីមួយៗ និងការបន្ថែមស្រដៀងគ្នាដែលបានស្នើសុំនេះ បង្ហាញឲ្យឃើញ ជាពិសេស ប្រភេទនៃសំណើរបស់ នួន ជា ដែលមិនអាចធ្វើយុត្តិកម្មបាន។

19. ជាងនេះទៀត តាមរយៈការលើកឡើងរបស់ នួន ជា ដែលថា វាជាការ "សំខាន់គឺថា អង្គជំនុំជម្រះគួរគោរពដល់ការវាយតម្លៃផ្ទាល់របស់មេធាវីការពារក្តីចំពោះពេលវេលា និងចំនួនទំព័រដែលចាំបាច់សម្រាប់ការអនុវត្តសិទ្ធិរបស់ នួន ជា យ៉ាងមានប្រសិទ្ធភាព"[62] នឹងនាំឲ្យមានលទ្ធផលមិនច្បាស់

---

[59] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា កថាខណ្ឌ១៥ *ដកស្រង់* ឯកសារ F13/2 សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប កថាខណ្ឌ ១៥។

[60] ឯកសារ F13/2 សំណុំរឿង០០២/០១ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប កថាខណ្ឌ១៥ (គូសបញ្ជាក់បន្ថែម)។

[61] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា កថាខណ្ឌ២៨។

[62] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា កថាខណ្ឌ៣៦។

លាស់។ ដូចគ្នាដែរ ឧទាហរណ៍ សហព្រះរាជអាជ្ញាអាចទទូចឲ្យអង្គជំនុំជម្រះតុលាការកំពូល ឯកភាពតាមតម្រូវការរបស់ខ្លួន ដោយមានចំនួនទំព័រ និងពេលវេលាសរុបដែលបានផ្ដល់ជូនមេធាវីការពាក្ដីនីមួយៗ ដើម្បីឲ្យមានសមភាព និងដើម្បីឆ្លើយតបឲ្យបានពេញលេញទៅរាល់បញ្ហាទាំងអស់ដែលត្រូវបានលើកឡើង។ ទោះជាយ៉ាងណា ការណ៍នេះមិនអនុវត្តបានទេ។ ការអនុញ្ញាតឲ្យភាគីកំណត់កាលបរិច្ឆេទកំណត់របស់ខ្លួន នឹងបង្កើតបានជាការចំអកមួយចំពោះដំណើរការនេះ ដែលជាការបញ្ចៀសនូវតួនាទីរបស់អង្គជំនុំជម្រះតុលាការកំពូល និងធានាឲ្យមានការពន្យារពេលដល់យុត្តិធម៌ និងប្រហែលជាអចិន្ត្រៃយ៍ក៏ថាបាន។

20. ជាចុងក្រោយ ការអះអាងរបស់ នួន ជា ដែលថា ការផ្ដល់ជូនណាមួយដែលតិចជាង ១០០០ ទំព័រ នឹងតម្រូវឲ្យគាត់ទម្លាក់ចោលចំនួនទឡ្ហីករណ៍បណ្ដឹងសាទុក្ខ "ដោយសារតែពុំមានពេលវេលា និងចំនួនទំព័រគ្រប់គ្រាន់"[63] មិនគួរត្រូវបានប្រើដើម្បីចាប់យកដំណើរការបណ្ដឹងសាទុក្ខជាចំណាប់ខ្មាំងនៃសំណើសុំហួសហេតុនោះទេ។ ជាការកត់សម្គាល់ នួន ជា បន្តអះអាងថា ប្រសិនបើការផ្ដល់ជូនអ្វីក៏ដោយ ដែលមិនមែនជាសំណើរបស់គាត់នោះ "មេធាវីការពារក្ដីត្រូវបង្ខំចិត្តពិចារណាស្នើសុំធនធានបន្ថែមដើម្បីឲ្យទាន់ថ្ងៃកំណត់ចុងក្រោយ សម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ"[64]។ ដោយសារតែការដាក់ឯកសារពីមុនៗរបស់មេធាវីការពារក្ដីដែលបានទទួលស្គាល់ទំហំក្រុមមេធាវីការពារក្ដីរបស់ នួន ជា[65] និងអង្គហេតុដែលថា មេធាវីជាតិបន្ថែមម្នាក់ទៀតត្រូវបានបន្ថែម [66] នួន ជា ហាក់ដូចជាកំពុងតែរៀបចំឲ្យមានក្រុម ដែលមានទំហំសម្រាប់សវនាការសម្រាប់បណ្ដឹងសាទុក្ខនេះ។ ការណ៍នេះស្របតាមការស្នើសុំរយៈពេល ១០,៥ខែ និង១០០០ទំព័រ ដែលត្រូវបានរចនាឡើងយ៉ាងច្បាស់ដើម្បីតវ៉ាឡើងវិញក្នុងសវនាការ ដែលមិនមែនជាគោលបំណងនៃបណ្ដឹងសាទុក្ខនោះទេ។

### *(vi) នួន ជា ពឹងផ្អែកលើការពិចារណាមិនពាក់ព័ន្ធ ដើម្បីធ្វើយុត្តិកម្មការបន្ថែមរបស់គាត់*

21. ការលើកឡើងរបស់ នួន ជា អំពី "ការពិចារណាពីបញ្ហាថវិការ" និង "ផែនការបញ្ចប់របស់ អ.វ.ត.ក" មិនពាក់ព័ន្ធសម្រាប់គោលបំណងនសការកំណត់ពេលវេលា និងចំនួនទំព័រកំណត់ឡើយ[67]។ មិនមានការចង្អុលបញ្ហាញថា បញ្ហាណាមួយក្នុងចំណោមបញ្ហាទាំងនេះកំពុងមានផល

---

[63] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា កថាខណ្ឌ៣៩។

[64] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា កថាខណ្ឌ៥២។

[65] *សូមមើល* ឯកសារ F41 ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ កថាខណ្ឌ៩-១១។

[66] *សូមមើល* សេចក្ដីប្រកាសព័ត៌មានដោយផ្នែកគាំពារការការពារក្ដី ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩។

[67] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា កថាខណ្ឌ២២។

ប៉ះពាល់ ឬ ក្នុងពេលអនាគត នឹងប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនេះឡើយ។ នួន ជា បានដកស្រង់ចេញពីសេចក្តីសម្រេចឆ្នាំ២០១៣ របស់អង្គជំនុំជម្រះតុលាការកំពូល លើដីកាបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២ របស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីគាំទ្រការលើកឡើងរបស់គាត់អំពីការព្រួយបារម្ភអំពីឧបសគ្គផ្នែកហិរញ្ញវត្ថុរំខានដែលអាចកើតមាន[68]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចពាក់ព័ន្ធទៅនឹងតម្រូវការដោះស្រាយបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង០០២ ថា មិនមាន "ឧបសគ្គផ្នែកហិរញ្ញវត្ថុ ឬផ្នែករដ្ឋបាលណាមួយរារាំងដល់បញ្ហានេះទេ"[69]។ ស្រដៀងគ្នានេះដែរ ផែនការបញ្ចប់របស់ អ.វ.ត.ក ដែល នួន ជា ផ្អែកលើនេះ[70] បានកត់សម្គាល់នៅក្នុងទំព័រមុខរបស់ខ្លួនថា ការប៉ាន់ទុកជាមុននៅក្នុងផែនការនេះ គឺជា "ការប៉ាន់ស្មាន" និង "ក្របខណ្ឌពេលវេលាមិនឆ្លុះបញ្ចាំងលក្ខខណ្ឌតម្រូវផ្នែកច្បាប់ថាតើព្រឹត្តិការណ៍សំខាន់ចាំបាច់ នឹងត្រូវឈានទៅដល់នៅពេលណានោះឡើយ"[71]។

22. ជាងនេះទៀត ការអះអាងរបស់ នួន ជា ដែលថា ក្រុមការពារក្តីរបស់គាត់ "មានឱកាសតិចតួចជាងសហព្រះរាជអាជ្ញាក្នុងការការពារក្តី"[72] គឺមិនត្រឹមត្រូវទេ។ នួន ជា គ្រាន់តែយោងទៅលើ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពរក្នុងសំណុំរឿង០០២ ដើម្បីគាំទ្រការអះអាងរបស់គាត់"[73]។ គាត់មើលរំលងថា សហព្រះរាជអាជ្ញា ត្រូវបានតម្រូវដោយច្បាប់ឱ្យដាក់ឯកសារទាំងអស់នេះ[74] ដែលឯកសារទាំងអស់នេះពាក់ព័ន្ធតែទៅនឹងដំណើរការស៊ើបអង្កេតតែប៉ុណ្ណោះ និងថាគាត់មានឱកាសឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា[75]។ ផ្ទុយទៅនឹងការអះអាងរបស់ នួន ជា មានគ្រប់ឱកាសដើម្បី

---

[68] ឯកសារ **F47** សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា កថាខណ្ឌ២២។

[69] ឯកសារ **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ កថាខណ្ឌ៧៤។

[70] ឯកសារ **F47** សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា កថាខណ្ឌ២៣។

[71] ផែនការបញ្ចប់របស់ អ.វ.ត.ក (វិសោធនកម្មទី ២០) ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ បញ្ចូលជាឯកសារភ្ជាប់លេខ ២ ទៅនឹងឯកសារ **F47** សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា។

[72] ឯកសារ **F47** សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា កថាខណ្ឌ ២៤។

[73] ឯកសារ **F47** សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា កថាខណ្ឌ ២៤។

[74] *សូមមើល* វិធាន ៥៣, ៥៥(៣), ៦៦(៥) នៃវិធានផ្ទៃក្នុង។

[75] *សូមមើល* ឧទាហរណ៍ ឯកសារ **D390/1/2/4** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ១៥-១៨។

ដាក់ចេញនូវសំណៅរបស់គាត់អំពីព្រឹត្តិការណ៍នានានៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល។ ថ្មីៗបំផុតនោះគឺសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលកម្រាស់ ៥៥១ ទំព័ររបស់គាត់ក្នុងសំណុំរឿង ០០២/២ គឺជាសេចក្តីរៀបរាប់ជំទាស់ទៅនឹងភ័ស្តុតាងដែលបានបង្ហាញ និងស្តាប់សវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលបានផ្តល់ឱកាសឱ្យ នួន ជា លើកឡើងនូវ "ការរៀបរាប់តាមបែប Manichean" ធំធេង និងលើកឡើងនូវរឿងនិទានសេរីនិយមអំពីប្រវត្តិសាស្ត្រកម្ពុជាដែលហៅថា "សត្វក្រពើ"[76]។

### *(vii) សំណើរបស់ នួន ជា សុំដាក់មួយភាសា គឺមិនសមរម្យទេ ដោយយោងទៅលើ ការបន្ថែមដែលបានស្នើឡើងនេះ*

23. សហព្រះរាជអាជ្ញាទទួលស្គាល់ថា ដូចក្នុងសំណុំរឿង០០២/០១[77] វាអាចជាការចាំបាច់ក្នុងការដាក់សារណាបណ្តឹងសាទុក្ខជាមួយភាសា។ ប៉ុន្តែ ភាពមិនសមហេតុផលនៃសំណើសុំរយៈពេល ១០,៥ ខែ និង១០០០ទំព័រ សម្រាប់សារណាបណ្តឹងសាទុក្ខរបស់គាត់ ត្រូវបានបង្ហាញដោយការប៉ាន់ទុកជាមុនរបស់គាត់ថា ការបកប្រែសារណាក្រាស់នេះ "អង្គភាពបកប្រែភាសានឹងត្រូវចំណាយពេលដល់ទៅ ១០ ខែ ដោយត្រូវធ្វើការពេញម៉ោង" ដែលទំនងជាត្រូវការ "ពេលវេលាបន្ថែមទៀតដែរដើម្បីដាក់បញ្ចូលគ្នា ធ្វើឱ្យមានភាពស៊ីសង្វាក់គ្នា និងកែសម្រួលទៅលើការបកប្រែដែលបានបញ្ចប់"[78]។ ការណ៍នេះនឹងមានន័យថា ពេលវេលាសម្រាប់បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី *តែឯង* ក្នុងសំណុំរឿង០០២/០២ នឹងប្រើពេលជិតពីរឆ្នាំ។ ដើម្បីផលប្រយោជន៍អំណះអំណាង ទោះបីជាអង្គភាពបកប្រែភាសាអាចបញ្ចប់ការបកប្រែក្នុងរយៈពេលត្រឹម *ពាក់កណ្តាល* នៃពេលវេលាដែលបានស្នើសុំក៏ដោយ ក៏វានៅតែប្រហែលជាពាក់កណ្តាលខែតុលា ឆ្នាំ២០២០ មុនពេលសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីបានបញ្ចប់។

### *(viii) សេចក្តីបញ្ចប់*

24. សហព្រះរាជអាជ្ញាធ្វើការបញ្ជាក់ឡើងវិញថា សារណាបណ្តឹងសាទុក្ខដែលត្រូវការរយៈពេលសមស្របគឺចាំបាច់ក្នុងករណីនេះ។ ដូចដែរ បានលើកឡើងពីមុន សហព្រះរាជអាជ្ញាពិចារណាថា រយៈពេលប្រាំខែ និង៣០០ទំព័រ សម្រាប់ក្រុមមេធាវីការពារក្តីនីមួយៗដើម្បីដាក់សារណាបណ្តឹង

---

[76] ឯកសារ E457/6/3/1 សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលដែលបានកែប្រែរបស់ នួន ជា ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧។

[77] ឯកសារ F9 សំណុំរឿង០០២/០១ សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រ កថាខណ្ឌ ១៨-១៩។

[78] ឯកសារ F47 សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា កថាខណ្ឌ៥០។

សាទុក្ខ ក្នុងមួយភាសា គឺមានភាពសមហេតុផល ដោយពិចារណាទៅលើ៖ (i) ទំហំសំណុំរឿង ០០២/០២ ធំជាង បើធៀបទៅនឹងសំណុំរឿង០០២/០១ ពាក់ព័ន្ធទៅនឹងប្រភេទ វិសាលភាព និង ចំនួនឧក្រិដ្ឋកម្មដែលត្រូវបានវិនិច្ឆ័យ។ (ii) រយៈពេល៣ខែ និង ២១០ ទំព័រ ដែលត្រូវបានអនុញ្ញាត សម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីក្នុងសំណុំរឿង០០២/០១ ដោយសារ ការផ្តល់ជូនការបន្ថែមរយៈពេល ៣០ថ្ងៃ និងប្រមាណជា ១៨០-២៤០ ទំព័រ។ (iii) ការអនុវត្ត របស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតដែលមានរឿងក្តីទំហំស្រដៀងគ្នានេះ។ (iv) សិទ្ធិ ទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំសារណា។ (v) តម្រូវឲ្យមានកិច្ចដំណើរការនីតិវិធីឆាប់ រហ័ស និង (vi) ផលប្រយោជន៍របស់ជនរងគ្រោះក្នុងការមើលឃើញយុត្តិធម៌ត្រូវបានបញ្ចប់ក្នុង ពេលវេលាមួយសមស្រប[79]។

25. ដោយយោងទៅតាមហេតុផលដូចគ្នានេះដែរ និងពិចារណាឃើញថាសហព្រះរាជអាជ្ញានឹងដាក់ សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួនក្នុងរយៈពេល និងចំនួនទំព័រកំណត់ដែលអាចអនុវត្តបាន ព្រម ទាំងបញ្ហាមួយចំនួនដែល នួន ជា និង ខៀវ សំផន ចង់ប្តឹង។ សហព្រះរាជអាជ្ញាស្នើឲ្យមានយ៉ាង ហោចណាស់ ៧០ភាគរយនៃចំនួនទំព័រសរុបរួម និង៥០ភាគរយនៃពេលវេលារួមដែលផ្តល់ជូន មេធាវីការពារក្តី សម្រាប់សហព្រះរាជអាជ្ញាធ្វើសារណាឆ្លើយតប[80]។ សហព្រះរាជអាជ្ញាស្នើថា ការកំណត់កាលបរិច្ឆេទសម្រាប់ដាក់ចម្លើយតបតែមួយភាសា គួរត្រូវបានយ៉ាងហោចណាស់៤៥ថ្ងៃ បន្ទាប់ពីមេធាវីការពារក្តីដាក់សារណាការពារជាភាសាខ្មែរ ដោយគោរពទៅតាមលក្ខខណ្ឌពីរភាសារបស់តុលាការ និងអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិមានពេលវេលាគ្រប់គ្រាន់ដើម្បីបញ្ជាក់ជំហររបស់ខ្លួន។

## IV. ដំណោះស្រាយដែលស្នើសុំ

26. ផ្អែកលើមូលហេតុដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះតុលាការ កំពូល៖ (i) បដិសេធសំណើរបស់ នួន ជា ស្នើសុំរយៈពេល ១០,៥ ខែ និង ១០០០ ទំព័រ សម្រាប់

[79] ឯកសារ **F45/2** ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ របស់ ខៀវ សំផន, កថាខណ្ឌ ១៧។

[80] ហេតុដូច្នេះ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលត្រូវផ្តល់ឲ្យក្រុមមេធាវីការពារក្តីនីមួយៗនូវរយៈពេល ៥ខែ និង ៣០០ទំព័រ សម្រាប់សារណាបណ្តឹងសាទុក្ខរបស់ពួកគេរៀងៗខ្លួននោះ (ដែលត្រូវជា ១០ ខែ និង ៦០០ទំព័រ នៃការរៀបចំសារណាបណ្តឹង សាទុក្ខរួមបញ្ចូលគ្នា) សហព្រះរាជអាជ្ញាស្នើសុំរយៈពេល ប្រាំខែ និង ៤២០ ទំព័រ ដើម្បីធ្វើការឆ្លើយតប ដោយកាលបរិច្ឆេទ កំណត់ចុងក្រោយយ៉ាងហោចណាស់ ៤៥ថ្ងៃ ក្រោយសំណៅជាភាសាខ្មែរនៃសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីទាំង ពីរត្រូវបានដាក់។

សារណាបណ្តឹងសាទុក្ខរបស់គាត់ និងផ្តល់ឱ្យនូវការបន្ថែមពេលវេលាចំនួន៥ខែ និងចំនួន៣០០ទំព័រកំណត់សមស្រប និង (ii) ផ្តល់ឱ្យសហព្រះរាជអាជ្ញា៧០ភាគរយនៃចំនួនទំព័រសរុបរួម និង៥០ភាគរយនៃពេលវេលារួមដែលផ្តល់ជូនមេធាវីការពារក្តី ដោយកំណត់កាលបរិច្ឆេទសម្រាប់ដាក់ឯកសារតែមួយភាសាមិនឱ្យលើសរយៈពេល៤៥ថ្ងៃ បន្ទាប់ពីឯកសារនៃសារណារបស់មេធាវីការពារក្តីជាភាសាខ្មែរត្រូវបានជូនដំណឹង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | [signature] |
| | **លោក William SMITH**<br>សហព្រះរាជអាជ្ញាអន្តរជាតិរង<br>ជួស<br>**លោកស្រី Brenda J HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិបម្រុង | | [signature] |